# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
## រយៈពេល ៣ ឆ្នាំ
## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : ត្លូងសែនជ័យ
ភូមិ : ត្លូង
ឃុំ : ពាមឆ្កោក
ស្រុក : ជលគីរី
ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# រយៈពេល ៣ ឆ្នាំ
# (២០០៨-២០១០)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | ត្លូងសែនជ័យ |
| ភូមិ | : | ត្លូង |
| ឃុំ | : | ពាមឆ្កោក |
| ស្រុក | : | ជលគីរី |
| ខេត្ត | : | កំពង់ឆ្នាំង |

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **ភ្លូងសែនជ័យ** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **២០** ខែ **មិថុនា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **ភ្លូងសែនជ័យ** មានទីតាំងស្ថិតនៅក្នុងភូមិ **ភ្លូង** ឃុំ **ពាមឆ្កោក** ស្រុក **ជលគីរី** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **៣៩៥** នាក់ ស្រីចំនួន **១៧៧** នាក់ និងមានគណៈកម្មការចំនួន **៧** នាក់ ស្រី **គ្មាន**។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **១៤៩** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

- ចុះហាមឃាត់ និងទប់ស្កាត់ការកាប់ព្រៃលិចទឹកបានចំនួន ៣៥ លើក
- ចូលរួមបង្ក្រាបការចិញ្ចឹមកូនត្រីឆ្តោ ត្រីរស់បានចំនួន ១៥ លើក
- ចូលរួមបង្ក្រាបការដាក់លូស្បៃមុងបានចំនួន ២២លើក
- ចូលរួមបង្ក្រាបបទល្មើសឆក់ ដោយចាប់បានជនល្មើស២នាក់ ក្បាលឆក់៣គ្រឿង និងទូក១ប្រវែង៥ម៉ែត្រ បញ្ជូនទៅការិយាល័យជលផលខេត្ត
- ចុះហាមឃាត់ការបូមបាចពង្រីងថ្លុក ត្រពាំងបានចំនួន ៣០ លើក
- ចុះចាប់ និងដកហូតមងពស់ថ្លាន់បានចំនួន ២៣ លើក
- ចុះដើរល្បាតជារៀងរាល់ខែ
- ប្រជុំពង្រឹងក្រុមល្បាត
- ទិញទូក៣គ្រឿងជួយទៅដល់គ្រូបង្រៀន និងវត្ត

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋៈ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **៦៨៤** នាក់ ប្រុស **៥១២** នាក់ ស្រី **១៧២** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **៦៧៧** នាក់ ខ្មែរឥស្លាមចំនួន **គ្មាន** អាណិកជនវៀតណាម **៧** នាក់ ។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១០ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ១ នាក់ ស្រី គ្មាន
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ២៥ នាក់ ស្រី ១០ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៣ នាក់ ស្រី ១ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ១ នាក់ ស្រី ១ នាក់

- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **៩៥ %**។ ក្រៅពីនេះមានអ្នកកាន់សាសនា អ៊ិស្លាម ប្រមាណ **គ្មាន %** សាសនាកាតូលិក **៥ %**
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **៥០** នាក់ ស្រី **២៥** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **គ្មាន** ស្រី **គ្មាន** កំរិតមធ្យមសិក្សា ចំនួន **គ្មាន** ស្រី **គ្មាន** និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន **គ្មាន**

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើនេសាទចំនួន ១០០ គ្រួសារ
- ធ្វើស្រែប្រាំងចំនួន ១៣៣ គ្រួសារ ទំហំ ៨០ ហិកតា
- ធ្វើវារីវប្បកម្មចំនួន ៣១ គ្រួសារ ទំហំ ០,៤៥ ហិកតា ឬចំនួន ១ បែ
- ដាំបន្លែចំនួន ៥ គ្រួសារ ទំហំ ១ ហិកតា
- ជាងផ្ទះចំនួន ៣ គ្រួសារ
- ធ្វើចំការចំនួន ១៥ គ្រួសារ ទំហំ ៥ហិកតា
- លក់ដូរ ចំនួន ៨ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ **ភ្លង់សែនជ័យ** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទ លេខ **១៤** និងជាដែននេសាទទឹកសាប។

កន្លែងនេសាទសហគមន៍ **ភ្លង់សែនជ័យ** មានទំហំ **៧០១** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹង **ភូមិថ្មីត្រង់ចំនុចក្បាលកោះយាយអុក**
- ខាងត្បូងទល់នឹង **ភូមិពាមពពិចត្រង់ចំនុចព្រែកផ្អុកអណ្ដែង**
- ខាងកើតទល់នឹង **ទន្លេក្រៅ និងភូមិស្វាយផ្អែមត្រង់ចំនុចទំនាបទូកទន្លេក្រៅ**
- ខាងលិចទល់នឹង **ភូមិអន្លង់អកចំនុចព្រែកយួន និងភូមិកន្លែងភេ**

៤. ផែននេសាទ

កន្លែងនេសាទសហគមន៍ **ភ្លូងសែនជ័យ** មានបឹងចំនួន **៧** ព្រែកចំនួន **២** ប្រឡាយចំនួន **១២** ត្រពាំងចំនួន **គ្មាន** បៀ ចំនួន **គ្មាន** និង មេទឹកចំនួន **៦**។

- បឹងឈ្មោះ **ត្រដកពង** ទំហំ ៣០០ម x ៦០ម នេសាទពីខែ កុម្ភៈ ដល់ខែ ឧសភា
- បឹងឈ្មោះ **ទទឹងថ្ងៃ** ទំហំ ១០០០ម x ៤០០ម នេសាទពីខែ មករា ដល់ខែ ឧសភា
- បឹងឈ្មោះ **កំពឹងពួយ** ទំហំ ៤៥០ម x ៧០ម នេសាទពីខែ មករា ដល់ខែ ឧសភា
- បឹងឈ្មោះ **វែង** ទំហំ ៥០០ម x ៥០ម នេសាទពីខែ មករា ដល់ខែ ឧសភា
- បឹងឈ្មោះ **ភ្លូង** ទំហំ ១៥០០ម x ១០០ម នេសាទពីខែ មករា ដល់ខែ ឧសភា
- បឹងឈ្មោះ **តាព្រូ** ទំហំ ៦០០ម x ៦០ម នេសាទពីខែ មករា ដល់ខែ ឧសភា
- បឹងឈ្មោះ **ផ្សេរាត** ទំហំ ១៧០០ម x ១៥០ម នេសាទពីខែ មករា ដល់ខែ ឧសភា
- ព្រែកឈ្មោះ **ភ្លូង** ប្រវែង ៣០០០ម x ១៥ម នេសាទពីខែ កញ្ញា ដល់ខែ មិនា
- ព្រែកឈ្មោះ **ភ្លុកអណ្ដែង** ប្រវែង ២៥០០ម x ១០ម នេសាទពីខែ កញ្ញា ដល់ខែ មិនា
- ប្រឡាយឈ្មោះ **មេម៉ាយ** ប្រវែង ៣០០ម x ១២ម នេសាទពីខែ កុម្ភៈ ដល់ខែ ឧសភា
- ប្រឡាយឈ្មោះ **ចុងបឹងផ្សេរាត** ប្រវែង ១៥០០ម x ៥ម អត់ធ្វើនេសាទទេ
- ប្រឡាយឈ្មោះ **តាប្រ** ទំហំ ៣០០០ម x ៣០ម នេសាទពីខែ កុម្ភៈ ដល់ខែ មិថុនា
- ប្រឡាយឈ្មោះ **យាយហង្ស** ទំហំ ៣០០ម x ១០ម នេសាទពីខែ កុម្ភៈ ដល់ខែ មិថុនា
- ប្រឡាយឈ្មោះ **ដៃស្រង៉ែ** ទំហំ ៥០០ម x ៣០ម នេសាទពីខែ កុម្ភៈ ដល់ខែ មិថុនា
- ប្រឡាយឈ្មោះ **ក្រចាប់** ទំហំ ៦០០ម x ២០ម នេសាទពីខែ កុម្ភៈ ដល់ខែ មិថុនា
- ប្រឡាយឈ្មោះ **គូខ្លែង** ទំហំ ១៥០ម x ១២ម នេសាទពីខែ កុម្ភៈ ដល់ខែ មេសា
- ប្រឡាយឈ្មោះ **ព្រែកអាមិន** ទំហំ ១០០ម x ១០ម នេសាទពីខែ មករា ដល់ខែ មេសា
- ប្រឡាយឈ្មោះ **ហៃហ៊ីម ២ខ្សែ** ទំហំ ១០០ម x ១០ម នេសាទពីខែ មករា ដល់ខែ មេសា
- ប្រឡាយឈ្មោះ **ព្រែកតាជឹម** ទំហំ ១៥០ម x ១៣ម នេសាទពីខែ មករា ដល់ខែ មេសា
- ប្រឡាយឈ្មោះ **យាយអ៊ុក** ទំហំ ៣០០ម x ៣៥ម នេសាទពីខែ មករា ដល់ខែ មេសា
- មេទឹកឈ្មោះ **ស្រង៉ែ** ទំហំ ៣០០០ម x ១០០០ម នេសាទពីខែ សីហា ដល់ខែ វិច្ឆិកា
- មេទឹកឈ្មោះ **គួរ** ទំហំ ៥០០០ម x ៥០ម នេសាទពីខែ មករា ដល់ខែ តុលា
- មេទឹកឈ្មោះ **តាកុលធំ** ទំហំ ៣០០០ម x ៩០០ម នេសាទពីខែ មករា ដល់ខែ តុលា
- មេទឹកឈ្មោះ **តាកុលតូច** ទំហំ ២០០០ម x ៣៥០ម នេសាទពីខែ មករា ដល់ខែ តុលា
- មេទឹកឈ្មោះ **សាំងវែង** ទំហំ ១០០០ម x ១០០ម នេសាទពីខែ មករា ដល់ខែ តុលា
- មេទឹកឈ្មោះ **សង្កែ** ទំហំ ១៥០០ម x ៦៨០ម នេសាទពីខែ មករា ដល់ខែ តុលា

- ស្រះចំនួន **៣០**ទំហំ ១០ម x ១៥ម នេសាទពីខែ សីហា ដល់ខែ មេសា

## គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- បឹងឈ្មោះ **បឹងភ្លូង** ( បណ្តោយ ៣០០០ ម ទទឹង ១៥០ ម)

## ឃ. ធនធានផលផល

- <u>**ប្រភេទត្រី :**</u> ត្រីរ៉ស់ ឆ្តោ ក្រាយ ប្រា ក្រពាត់ សណ្តាយ ដំរី កាប ក្រម៉ម កញ្ចុះ រៀល ស្លាត ក្រាញ់ កំភ្លាញ ច្រវ៉ា ក្រុស ព្រួល កន្ធននីយ ចេក ក្រឹម កញ្ជាញ់ច្រាស់ កន្ត្រង់ប្រេង ចង្កែង លិញ កន្ទាស់ភ្លុក កាហែ អំពិលទុំ កន្ទ្រប់ កំភ្លៀវ កេះ ឆ្លាំង ទ្រនេល ខ្មាន់ ឆ្ពិន រលកស អង្កត់ប្រាក់ ស្រកាក្តាម កំពឹសច ព្រលូង កំពត ច្រលឹង បណ្តូលអំពៅ ផ្ទោង កន្ធរ។
- <u>**ប្រភេទវារីសត្វ :**</u> ពស់ ភេ កង្កែប ហ៊ីង គីង្គក់ តាឡនតន ក្អាត់ ប្រវឹក កុក ក្រសា ទោម ទុង មាន់ទឹក មាន់ទោ ព្រហិត កំពីងដូង ក្អែកទឹក ស្មោញ ននាល ត្រយ៉ង ត្រដក់ លលក ចាប អន្សង ក្រពើ កន្ត្រង បង្គួយ ផ្លែន ស្កា សំពោច ខ្លាត្រី កណ្តុរ ខ្វែក ខ្លែងស្រាក់ មាម ទីទុយ គូក ក្លុំ រហាត់ទឹក គ្រវែងវែក ។
- <u>**ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ**</u> : ព្រលិត ត្រកួន រំចង ចក កំប៉ោង ស្មោ កន្ទាំងហៃ កំពីងពួយ ស្រម៉ៅ រំពាក់ទឹក ក្រចាប់ សារ៉ាយ ស្លាបចង្វា កក់ បន្លាយួន រាំង បបួយ ចង្កែង ទានព្រៃ ញ ត្រស់ សណ្តាន់ រញ្ជៀ គ្លេ សាវម៉ាវ ត្រអើក ថ្លើមអណ្តើក ខ្នាយមាន់ ដូងព្រះ វល្លិត្រី វល្លិជុយ វល្លិប្រេង ទន្លា ថ្វាន់ បន្លាស្អិត សាយ ត្រដក ក្រវ៉ាន់ទឹក ក្រ ស្នាយទឹក រ៉ៃទឹក តាដិត ភ្អែកព្រាប ជើងចាប ក្រវ៉ាន់ ទ្រនំបង្គួយ ត្រែង ស្មៅពត ស្មៅចិញ្ចៀន ទ្រមែង ក្រប៉ៅ ក្រចៅ ក្រជីប ប្រម៉ាត់ដី ជើងតឹកកែ ជើងបង្កង ខ្ទាញ់ គែលលក ឫស្សី សក់សេះ ក។

# ៤. ការធ្វើនេសាទ

## ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៣២១ នាក់ ស្រី ១៦៨ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍ចំនួន ៤ នាក់ ស្រី ២ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៤០០ នាក់ ស្រី ១០០ នាក់

## ៩. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ១ដៃ=៨០ម | ២ដៃ x ៧០ន=១៤០ | ចំនួន=១១២០០ម<br>ក្រឡា=២,៥សម-៤សម<br>ជំរៅ=១,២ម | មករា-ធ្នូ |
| លាន់ | គ្រឿង | ៣០គ្រឿង x ១០ន= | ចំនួន=៣០គ្រឿង | កញ្ញា-តុលា |
| សន្ទូចរនង | ផ្លែ | ៥០០ផ្លែ x ២០ន= | ចំនួន=១០០០០ផ្លែ<br>លេខ១១-១៤ | សីហា-ធ្នូ |
| លប | គ្រឿង | ៥គ្រឿង x ១០ន= | ចំនួន=៥០គ្រឿង<br>ក្រឡាត្រៀម= ៣សម<br>កំពស់=១.២ , មុខកាត់=0.៦ម | មករា-ធ្នូ |
| ឡើ | វង់ | ៥០វង់ x ៥ន= | ចំនួន=២៥០វង់ | កញ្ញា-មករា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៣០ គ្រឿង | ១០០-២០០ គ.ក្រ | |
| កាណូត | ៤៣ គ្រឿង | ១០០០-៣០០០ គ.ក្រ | ១៥-១៨ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មងពាក់ | ១ដៃ=៨០ម | ៥០ន x ៨០ ម | ចំនួន=៤០០០ម , ក្រឡា=២,៥សម-៤សម<br>ជំរៅ=១,២ម |
| មងបណ្តែត | ១ដៃ=១៥០ម | ៤៥ ន x ១៥០ ម | ចំនួន=៦៧៥០ ម ,ក្រឡា=២,៥សម<br>ជំរៅ=១,២ម |
| សន្ទូចរនង | ផ្លែ | ៣០ ន x ៨០០ផ្លែ | ចំនួន=២៤០០០ ផ្លែលេខ ១៤ |
| លប | គ្រឿង | ៣គ្រឿង x ២០ន= | ចំនួន=៦០ គ្រឿង , ក្រឡាត្រៀម= ៣សម<br>កំពស់=១.២ , មុខកាត់=0.៦ម |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ១៨ | ៥០០-១២០០ គក្រ | ៥-៦សេះ |
| ទូកចែវ | ៣២ | ៥០០-៨០០ គក្រ | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ដៃ | ២០០ន x ២ដៃ = ៤០០ន | ៤០០ន x ៨០ម = ៣២.០០០ |
| សន្ទូចរនង | ផ្លែ | ២០០ន x ៣០០ផ្លែ = ៦០០០០ ផ្លែ | ៦០០០០ផ្លែ x ១ម = ៦០.០០០ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូក | ២គ្រឿង | ២០០-៣០០ គក្រ | ៥សេះ |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ២២.៥០០ គក្រ | ២២.៥០០ គក្រ | ៤៥.០០០ គក្រ |
| ក្តាម ខ្យង | ៤៥.០០០ គក្រ | ៣៥.០០០ គក្រ | ៨០.០០០ គក្រ |

# ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **ភ្លងសែនជ័យ** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាពនិងធានាការបែងចែកផលប្រយោជន៍ធនធាន ជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការ ចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងទទឹងថ្ងៃ | **មករា-ឧសភា** | មងរាយ | ចំនួន=១៥០០ម ក្រឡា=២,៥-៥,៥សម ជំរៅ=១,២ម | ១៥ នាក់ | ១នាក់អនុញ្ញាត ១០០ម |
| បឹងភ្លុង | **មករា-មិថុនា** | សន្ទូចរនង | ៣០០០ ផ្លែ លេខ១៣ | ២០ នាក់ | ១នាក់អនុញ្ញាត ១៥០ផ្លែ |
| បឹងកំពីងពួយ | **មករា-ឧសភា** | មង | ចំនួន=១៥០០ម ក្រឡា=២,៥-៥,៥សម ជំរៅ=១,៥ម | ៣០ នាក់ | ១នាក់អនុញ្ញាត ៥០ម |

### គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ព្រែកភ្លុង | ៣០០០ x ១០ម | ២០០០ x ២ម x ១ម | ស្តារព្រែកភ្លុង | ឧសភា ២០០៩ | កក្កដា ២០១០ | |

### គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទ នៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងភ្លូង | ៣០០ x ១០០ម | បឹងអភិរក្ស | - ចុះកំណត់<br>- ប្រជុំផ្សព្វផ្សាយ<br>- ចុះកំណត់ព្រំប្រទល់<br>- ទិញសំភារៈ<br>- ចុះអនុវត្ត<br>- រត់ស្លាកសញ្ញា | កុម្ភៈ ២០០៩ | កក្កដា ២០១០ | |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើ ដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹកឡើងវិញនៅជុំមាត់បឹងភ្លូង | ២ហិចតា | | - ធ្វើស្លាកសញ្ញាចំនួន៥០ បោះកន្លែងព្រៃដែលបានកាប់ហើយដុះឡើងវិញ | ២០០៩ | ២០១០ | |

### គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ ប=៨ម ទ=៥ម | ១០ ស្រះ | ត្រីប្រា | ១៥០០០កូន<br>១ស្រះ=១៥០០កូន | កុម្ភៈ ២០០៩ | កក្កដា ២០០៩ |

## ក-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រជុំផ្សព្វផសាយ | មករា ២០០៩ | សីហា ២០១០ | ១៧៧.៥០០រ | |
| ភាគទានប្រចាំឆ្នាំ ៥០០រៀល | ប្រមូលភាគទានប្រចាំឆ្នាំ | មិនា ២០០៩ | ធ្នូ ២០១០ | ១៧៧.៥០០រ | ៥០០រ/នាក់ |
| ជំនួយសម្បុរសជន និងអង្គការនានា | CCD | | ២០១០ | | |

## ក-៧ ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាពសហគមន៍

| ប្រភេទមុខរបរ | សកម្មភាព និងចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ចិញ្ចឹម ត្រី, ជ្រូក, មាន់ | មាន់ ៣ក្បាល/គ្រួសារ (១០គ្រួសារ)<br>ជ្រូក២ក្បាល/គ្រួសារ (១០គ្រួសារ) | ២០០៩ | ២០១០ |
| ដាំបន្លែ (ននោង, សណ្តែកគួ, ស្ពៃខៀវ, ស្ពៃចង្កឹះ...) | ២០ គ្រួសារ | ២០០៩ | ២០១០ |
| បណ្តុះផ្សិត | ១គ្រួសារ/២រង (២០គ្រួសារ) | ២០០៩ | ២០១០ |

## ក-៨ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ៩ បង្គោល (PIU) | តាមចំណុចដែលបានកំនត់ក្នុងផែនទីសហគមន៍ | គណៈកម្មការសហគមន៍នេសាទ | កុម្ភៈ ២០០៩ | មិនា ២០០៩ | ត្រូវការជំនួយ និងការសហការពី ស្ថាប័នជំនាញ និងអង្គការនានា |

## ក-៩ ផែនការផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹង

| ប្រធានបទ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| លក្ខន្តិកៈនិង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៣ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| សារៈប្រយោជន៍នៃធនធានធម្មជាតិ និងបរិស្ថាន | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |

| | | | |
|---|---|---|---|
| ផែនទីកំណត់ព្រំប្រទល់កន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៨ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| ផែនការគ្រប់គ្រងកន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងដល់ការគ្រប់គ្រងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| ការគ្រប់គ្រង និងសារៈប្រយោជន៍នៃព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |
| ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ២ នៃឆ្នាំនិមួយៗ | និងរដ្ឋបាលជលផល CFC |

## គ-១០ ផែនការពង្រឹងសមត្ថភាពសហគមន៍

| ផែនការ | ប្រធានបទ/ជំនាញ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ពង្រឹងស្ថាប័ន និងការងារគ្រប់គ្រង | ការធ្វើកំណត់ហេតុ និង របាយការណ៍ | គណៈកម្មការស.ន | កុម្ភៈ ២០០៨ | និងរដ្ឋបាលជលផល CFC |
| | របៀបសរសេរខិតរដ្ឋបាល | គណៈកម្មការស.ន | កក្កដា ២០០៨ | និងរដ្ឋបាលជលផល CFC |
| | រៀបចំទុកដាក់ឯកសារសហគមន៍ និងរបៀបកត់ត្រាប្រចាំថ្ងៃ | គណៈកម្មការស.ន | មិថុនា ២០០៨ | និងរដ្ឋបាលជលផល CFC |
| | ការគ្រប់គ្រងថវិកា | គណៈកម្មការស.ន | កុម្ភៈ ២០០៨ | និងរដ្ឋបាលជលផល CFC |
| | ការដោះស្រាយទំនាស់ | គណៈកម្មការស.ន | | និងរដ្ឋបាលជលផល CFC |
| | ការទំនាក់ទំនង និងសរសេរសំណើសុំថវិកា | គណៈកម្មការស.ន | មេសា ២០០៨ | និងរដ្ឋបាលជលផល CFC |
| | រៀបចំបណ្តាញសហគមន៍ | គណៈកម្មការស.ន | សីហា ២០០៨ | និងរដ្ឋបាលជលផល CFC |
| | ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | គណៈកម្មការស.ន | ១ដង/ឆ្នាំ | និងរដ្ឋបាលជលផល CFC |
| បណ្តុះបណ្តាលបច្ចេកទេស | បណ្តុះ និងដាំព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | កញ្ញា ២០០៨ | និងរដ្ឋបាលជលផល CFC |
| | ចិញ្ចឹមត្រី និងសត្វ | សមាជិក និង | កុម្ភៈ ២០០៨ | និងរដ្ឋបាលជលផល CFC |

| | | | | |
|---|---|---|---|---|
| | | គណៈកម្មការស.ន | | |
| | បណ្តុះផ្សិត | សមាជិក និង<br>គណៈកម្មការស.ន | មិនា ២០០៨ | និងរដ្ឋបាលជលផល<br>CFC |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែល ទាក់ទងនឹងបច្ចេកទេសជលផលដូចជា៖ ការធ្វើផែនការ កន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរក ថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួល បានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្លុងសែនជ័យ រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | - ផ្សព្វផ្សាយផែនការប្រើប្រាស់ឧបករណ៍នេសាទដល់សមាជិកសហគមន៍ទាំងអស់ និងអ្នកមកពីខាងក្រៅ<br>- ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំ | - សមាជិក និងអ្នកមិនមែនជាសមាជិកសហគមន៍ទាំងអស់បានជ្រួតជ្រាបពីផែនការ<br>- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ នាំឱ្យត្រីមានការកើនឡើង | - ចំណាយលើការផ្សព្វផ្សាយ ១០០ ដុល្លា<br>- ចំណាយលើការចុះល្បាត ត្រួតពិនិត្យតាមដាន ១៥០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៩ | ២០១០ | |
| ២. ការកែលំអដែននេសាទ | បឹងភ្លុង, ជីកជំរៅ,ទំហំ ៣០០០មx១៥០មx១,៦ម | -ជីវភាពកើនឡើង<br>-ជីវភាពសំបូររុងរឿង<br>-រក្សាមេពូជ | ២០០០ ដុល្លា | -អង្គការ<br>-ជំនាញ | ឧសភា ២០០៩ | កក្កដា ២០១០ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | បឹងភ្លុង, ជីកជំរៅ,ទំហំ ៣០០០មx១៥០មx១,៦ម | -ជីវភាពកើនឡើង<br>-ជីវភាពសំបូររុងរឿង<br>-រក្សាមេពូជ | ២០០០ ដុល្លា | -អង្គការ<br>-ជំនាញ | កុម្ភៈ ២០០៩ | កក្កដា ២០១០ | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | - ដាំព្រៃលិចទឹកទំហំ ១៥ ហតរាំង,ត្រស់ | - រក្សាមេពូជត្រី<br>- សំបូរសត្វស្លាប និងធនធានជលផល ។<br>- ជីវភាពប្រជាជនកើនឡើង | ៣០០ ដុល្លា | | ២០០៩ | ២០១០ | |
| ៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | - ចិញ្ចឹមត្រីប្រា ១០ ស្រះ (១៥០០០កូន) | - ជីវភាពប្រជាជនកើនឡើង<br>- បង្កើនជីវភាពគ្រួសារ | ១០០ ដុល្លា | - សប្បុរសជន<br>- អង្គការ និង ជំនាញ | កុម្ភៈ២០០៩ | កក្កដា ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | - ប្រមូលប្រាក់សមាជិកភាព និង ភាគទានប្រចាំឆ្នាំ<br>- ស្វែងរកជំនួយបន្ថែមពីអង្គការ និងសប្បុរសជននានា | - សមាជិកស.នទាំងអស់នឹងបង់ប្រាក់តាមការកំនត់ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>- អង្គការ និងសប្បុរសជននានា នឹងជួយគាំទ្រតាមរយៈការផ្តល់សំភារៈ និងថវិកាដល់ស.ន | - គ្មានការចំណាយ | - | ២០០៩ | ២០១០ | |
| ៧- ផែនការបង្កើនមុខរបរ ទ្រទ្រង់ជីវភាព | - វិភាគ និងចាត់អាទិភាព ជំរើស មុខរបរចិញ្ចឹមជីវិត<br>- ស្វែងរកអង្គការ ស្ថាប័នគាំទ្រ<br>- រៀបចំសំណើសុំថវិកា | - ជំរើសមុខរបរចិញ្ចឹមជីវិតត្រូវបានកំនត់ និងចាត់អាទិភាព<br>- សំណើសុំថវិកាត្រូវបានរៀបចំ និងទទួលបានការគាំទ្រពីអង្គការនានា | - ចំណាយសរុប ៥០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៩ | ២០១០ | |
| ៨- ផែនការបោះបង្គោល ព្រំប្រទល់សហគមន៍ | - សហការជាមួយជំនាញផែនទីកំនត់ទីតាំងត្រូវបោះបង្គោល<br>- ស្វែងរកថវិកាគាំទ្រ | - បង្គោលត្រូវបានបោះត្រឹមត្រូវតាមចំនុចដែលកំនត់លើផែនទី<br>- ស.នមានព្រំប្រទល់ច្បាស់លាស់ កាត់បន្ថយជម្លោះ | - ចំណាយសរុប ៣០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់ ស.គ | កុម្ភៈ ២០០៩ | មិនា ២០១០ | |
| ៩- ផែនការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង | - ផ្សព្វផ្សាយឱ្យស.គបានយល់ដឹងពី លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធ និងស.ន | - ស.គបានយល់ដឹង និងអនុវត្តតាម | - ១០០ ដុល្លា | ជំនួយអង្គការ និងសប្បុរសជននានា ថវិកាអភិវឌ្ឍន៍ឃុំ ប្រាក់បដិភាគរបស់ស.គ | មករា ២០០៩ | ធ្នូ ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០- ផែនការពង្រឹងសមត្ថភាពសហគមន៍ | - បង្កើនសមត្ថភាពស.គតាំងជំនាញ គ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ស.គចេះជំនាញផ្សេងៗទាក់ទិននិងការងារគ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ១០០ ដុល្លា | - ជំនួយអង្គការនិងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៩ | ធ្នូ ២០១០ | |

## តារាងកម្មវិធីការងារ

| សកម្មភាព | ឆ្នាំ ២០០៨ 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ | | | | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

| សកម្មភាព | ឆ្នាំ ២០០៩ 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | | | | | ■ | ■ | ■ | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ | | ■ | ■ | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | | | | | | | | | | | | |

| សកម្មភាព | ឆ្នាំ ២០១០ 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ | | | | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | | | | | | | | | | | | |

បានឃើញ និងបញ្ជូនមក

លោកនាយសង្កាត់រដ្ឋបាលជលផល

នាយសង្កាត់រដ្ឋបាលជលផល.........

.........ថ្ងៃទី...17...ខែ...10...ឆ្នាំ ២០០8

លេខ :.................

បានឃើញ

មេឃុំ.............

.................ថ្ងៃទី ...17...ខែ...10...ឆ្នាំ ២០០8

លេខ :.............

.........ថ្ងៃទី...17...ខែ...10...ឆ្នាំ ២០០8

ប្រធានគណៈកម្មការសហគមន៍នេសាទ

លេខ :.............

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

.........ថ្ងៃទី...27...ខែ...11...ឆ្នាំ ២០០8

**នាយអធិការដ្ឋានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋានរដ្ឋបាលជលផល

.........ថ្ងៃទី...21...ខែ...10...ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល**